# តុំ (ឧបករណ៍នេសាទមួយបែប)

នៅតាមនិគមជនបទខ្មែរ វប្បធម៌ក្នុងការនេសាទមានរបៀបរបបដូចគ្នាខ្លះ និងមិនដូចគ្នាខ្លះ។ គួរឱ្យចាប់អារម្មណ៍នោះ នៅតាមតំបន់នីមួយៗតែងនិយមប្រើប្រាស់ឧបករណ៍នេសាទតាមបែបផែនរបស់ខ្លួន ហើយឧបករណ៍នេសាទខ្លះ អ្នកនៅតំបន់ផ្សេងមិនស្គាល់ក៏មាន។ ចំពោះអ្នកស្រុករស់នៅតាមដងស្ទឹងសែន ខេត្តកំពង់ធំ ការនេសាទត្រីតូចៗគេនិយមប្រើប្រាស់ឧបករណ៍មួយដែលមានឈ្មោះថា "**តុំ**"។ សព្វថ្ងៃ ឧបករណ៍នេសាទមួយប្រភេទនេះ កំពុងបន្តផលិតសម្រាប់លក់នៅភូមិវាលព្រីងក្រោម ឃុំឈើទាល ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ តើឧបករណ៍នេសាទមួយប្រភេទនេះមានលក្ខណៈបែបណាខ្លះ?

តុំ ជាឧបករណ៍នេសាទមួយប្រភេទដែលធ្វើអំពីឫស្សី មានរាងកំប៉ោង មាត់ដូចចូផ្កា និងមានប្រឹសនៅខាងក្រោម ប្រើប្រាស់សម្រាប់ដាក់យកត្រីតូចៗ។ ជាទូទៅ តុំមានប្រវែងខ្លួនប្រមាណ ៣០ ស.ម. និងមានកម្ពស់ប្រមាណ ៦០ ស.ម.។ តាមទម្លាប់របស់អ្នកភូមិវាលព្រីងក្រោម ដើម្បីផលិតតុម្ពបានគេចាំបាច់ត្រូវការឫស្សីចាស់មកត្បាញ រីឯឫស្សីដែលនៅខ្ចីត្បាញមិនកើតឡើយ។ ឫស្សីទៀតសោត បើកាលណាគេទើបតែកាប់ថ្មីៗឬនៅស្រស់ល្អ គេមិនចាំបាច់យកទៅត្រាំទឹកឡើយ ពោល គឺអាចពុះច្រៀកយកមកត្បាញជាតុំបានតែម្ដង។ ប៉ុន្តែ ប្រសិនបើឫស្សីនោះកាប់ទុកយូរហើយ គេមិនអាចយកមកត្បាញបានឡើយ ព្រោះឫស្សីនោះនឹងល្អួតនៅពេលច្រៀក។ ពោល គឺត្រូវតែយកទៅត្រាំទឹកចំនួនពីរឬបីយប់សិន ទើបយកមកត្បាញបាន។ ក្នុងឫស្សីមួយដើម គេអាចពុះច្រៀកត្បាញជាតុំបានចំនួន ៥ ឬ ៦។

ជាដំបូង គេត្រូវយកកាំបិតបន្ទោះបិតឫស្សីឱ្យចេញជាចម្រៀកតូចៗ (បន្ទោះ) ប្រវែង ៨០ ស.ម. សម្រាប់ធ្វើជា "**ត្រៀមបញ្ឈរ**"។ បន្ទាប់មក គេត្រូវយកត្រៀមបញ្ឈរនោះមកផ្គុំខ្វែងបញ្ចូលគ្នាឱ្យគ្នាចេញជារាងមូលដើម្បីធ្វើបាត។ រួចមក គេចាប់ផ្ដើមធ្វើប្រឹសនៅចំពាក់កណ្ដាលបាត ដោយប្រើជន្ទួញឈើធ្វើជាពុម្ព ហើយក្រងប្រឹសនោះឱ្យចេញរាងមូលដោយរុំព័ទ្ធជាមួយវល្លិកញ្ចួញ។ បន្ទាប់មកទៀត គេចាប់ចុងត្រៀមបញ្ឈរទាំងអស់ផ្គុំឡើងមកលើ (ហៅថា "**តំឡើង**") ដោយយកវល្លិចងផ្នែកខាងលើជាបណ្ដោះអាសន្ន ដើម្បីងាយស្រួលត្បាញផ្នែកខ្លួនរបស់តុំ។ គេត្បាញតួខ្លួនដេញពីបាតឡើងមកខ្លួន ដោយត្រូវក្រងវិលជុំឱ្យចេញជារាងមូលទ្រវែង។ ជាចុងក្រោយ គេក្រង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

***អត្ថបទ៖ តុំ (ឧបករណ៍នេសាទមួយបែប)***

*បន្ទោះឫស្សីភ្ជាប់គ្នាពីខ្លួនឡើងបន្តមកដល់ស្មា ក និងមាត់របស់តុម្ពឱ្យចេញជារាងដូចថូផ្កា ដែលគេហៅថា "**ត្រៀមផ្កេក**"។*

*ជាធម្មតា ក្នុងគ្រួសារមួយ (ប្ដីប្រពន្ធ) អាចត្បាញតុំបានចំនួន ២ ក្នុងមួយថ្ងៃ។ ប៉ុន្តែ បើមានតម្រូវការបញ្ជាទិញច្រើនពីអតិថិជន គេអាចត្បាញតុំបានចំនួន ៤ ក្នុងមួយថ្ងៃ ពោល គឺបន្តធ្វើនៅពេលយប់បន្ថែមទៀត។ តុំដែលត្បាញទាំងអម្បាលម៉ាន ច្រើនលក់ចេញទៅអ្នកនេសាទនៅក្នុងស្រុកសណ្ដាន់ ស្រុកប្រាសាទសំបូរ ស្រុកកំពង់ស្វាយ ស្រុកស្ទោង និងមួយផ្នែកលក់ចេញទៅខេត្តព្រះវិហារផង ដែលក្នុងតុំមួយអាចលក់ចេញក្នុងតម្លៃ ១៧,០០០ រៀល។*

*ជាទូទៅ គេប្រើប្រាស់តុំសម្រាប់នេសាទយកត្រីនៅតាមបឹង និងស្ទឹង។ តាមរបៀបបុរាណកាលណាគេដាក់តុំយកត្រីនៅតាមមាត់បឹង គេត្រូវបោះបង្គោលឈើចំនួន ២ ដើម រួចស៊កតុំចូលប្រឡោះបង្គោលទាំងពីរ ដោយចងព័ទ្ធកតុំរុំភ្ជាប់ជាមួយបង្គោលឈើទាំងពីរដើមនោះ ហើយយកស្មៅ ឬកំទេចកំទីស្លឹកឬមែកឈើតូចៗគ្របពីលើមាត់តុំ។ ប៉ុន្តែ បច្ចុប្បន្ននេះបើនៅរដូវទឹកសម្រកអ្នកនេសាទដោយប្រើតុំនៅតាមដងស្ទឹងសែន គេច្រើនយកខ្សែចងភ្ជាប់កតុំតម្រៀបគ្នាដោយប្រើប្រាស់ដំបងឬដបទឹកបីឬបួន ដើម្បីកុំឱ្យតុំលិចចូលទៅក្នុងទឹក។ តុំនីមួយៗ គឺសុទ្ធតែមាននុយ ដូចជា ល្ង ពងអង្ក្រង កន្ទក់ ឬបាយ (បើនុយបាយត្រូវបុកលាយជាមួយកន្ទក់ឬល្ង និងប័ន់ជាមុនសិន) រុំជាមួយក្រណាត់ ហើយគេដាក់មាត់ឡើងទៅលើផុសចេញពីទឹក។ ចំណែកបាតក្រោមលិចចូលក្នុងទឹកត្រឹមពាក់កណ្ដាលខ្លួន។ ម៉្លោះហើយ នៅពេលត្រីតូចៗ ដូចជា ត្រីចង្វា ត្រីស្លឹកឫស្សី និងត្រីផ្សេងៗទៀតដែលចង់ចូលស៊ីនុយនោះ វានឹងចូលទៅក្នុងតុំតាមប្រឹសខាងក្រោមដែលលិចក្នុងទឹក ហើយត្រីទាំងនោះមិនចេញមកវិញទេ។*

*ជារួមមក ហត្ថកម្មបែបប្រពៃណីនេះ កំពុងដំណើរការជាប្រក្រតីនៅភូមិវាលព្រីងក្រោម។ ប៉ុន្តែ ប្រការគួរឱ្យព្រួយបារម្ភជំនាញនេះកំពុងតែប្រឈមនឹងការបាត់បង់ជាបណ្ដើរៗ ដោយសារតែការងារនេះមានភាពលំបាក និងកង្វះអ្នកបន្តវេន។ ជាក់ស្ដែង កាលដើមឡើយនៅភូមិនេះ មានសិប្បករតម្បាញតុំច្រើនគ្រួសារណាស់ តែមួយរយៈកាលចុងក្រោយនេះ មានគ្រួសារជាច្រើនបានបោះបង់ជាបន្តបន្ទាប់ ពោល គឺបច្ចុប្បន្ននៅសល់តែ ៤ គ្រួសារប៉ុណ្ណោះដែលកំពុងបន្តជំនាញហត្ថកម្មនេះ ដោយបន្តធ្វើមិនគិតរដូវប្រាំង ឬវស្សាឡើយ។*

*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*



រូបលេខ១៖ បិតឫស្សីឱ្យចេញជាចម្រៀកតូចៗ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២-៣៖ ត្បាញបាត



រូបលេខ៤-៥៖ តម្លើងដើម្បីត្បាញខ្លួន

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៦-៧៖ ត្បាញមាត់ខាងលើ និងរូបតុំរួចរាល់ទាំងស្រុង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី